**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ០៨៤៨......[illegible]/ គ.ជ.អ.ប

ថ្ងៃច័ន្ទ ៥រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី.....០៧.........ខែកញ្ញា......ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១

លេខាធិការដ្ឋាន គ.ជ.អ.ប មានកិត្តិយសសូមជម្រាបដល់អ្នកទទួលការទាំងអស់ឱ្យបានជ្រាបថា នៅខែកញ្ញា ឆ្នាំ២០២០ ខាងមុខនេះ រាជធានី ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០២១ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២១។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (សំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី(ប្រឡាយ ទំនប់ ទ្វារទឹកខ្នាតតូច ផ្លូវដីស ផ្លូវក្រួសក្រហម លូមូល...។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខាគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងយ៉ាងតិច ០២ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ គណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលរាជធានី ខេត្តដើម្បីពិនិត្យ និងសម្រេច។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅរាជធានី ខេត្តដែលខ្លួនធ្វើអាជីវកម្មអចិន្ត្រៃយ៍។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តដោយឥតបង់ថ្លៃ។

ការប្រកាសជូនដំណឹងស្តីពីការដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការដោយឡែកសម្រាប់រាជធានី ខេត្តនីមួយៗ មានបិទផ្សាយនៅលើក្តារព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

លេខាធិការដ្ឋាន

ចាំង ឫទ្ធីរ៉ែន